**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

# ការជ្រើសរើស
# មេភូមិ និងជំនួយការមេភូមិ

**រៀបរៀងដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

**ខែមេសា ឆ្នាំ២០០៦**

## មាតិកា


អារម្ភកថា ១

**១. អំពីភូមិ ៣**

១.១. និយមន័យ ៣

១.២. លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបំបែកភូមិ ការបង្រួមភូមិ និងការរំសាយភូមិ ៣

១.២.១. លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ៣

១.២.២. លក្ខណៈវិនិច្ឆ័យនៃការបំបែកភូមិ ៤

១.២.៣. លក្ខណៈវិនិច្ឆ័យនៃការរំសាយ និង ការបង្រួមភូមិបញ្ចូលគ្នា ៤

១.៣. នីតិវិធីនៃការបង្កើតភូមិថ្មី ការបំបែកភូមិ ការបង្រួមភូមិ និងការរំសាយភូមិ ៥

**២. តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ភូមិ ៧**

២.១. តួនាទី និងភារកិច្ចមេភូមិ ៧

២.២. តួនាទី និងភារកិច្ចជំនួយការមេភូមិ ៩

២.៣. របៀបរបបការងាររបស់ភូមិ ១០

២.៤. ទីកន្លែងធ្វើការងារ ១១

**៣. អាណត្តិការងារ និងការបាត់បង់មុខតំណែង ១២**

៣.១. អាណត្តិការងារ ១២

៣.២. ល័ក្ខខ័ណ្ឌនានានៃការបាត់បង់មុខតំណែង ១២

៣.៣. នីតិវិធីក្នុងការបញ្ឈប់ពីមុខតំណែង ១៣

**៤. បែបបទ និងនីតិវិធីនៃការជ្រើសរើសមេភូមិ ១៥**
៤.១. ភូមិដែលត្រូវជ្រើសរើសមេភូមិ ១៥
៤.២. លក្ខណសម្បត្តិនៃបេក្ខជនមេភូមិ ១៥
៤.៣. នីតិវិធីជ្រើសរើសមេភូមិ ១៦
៤.៣.១. ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ១៦
៤.៣.២. ការជ្រើសរើសបេក្ខជនមេភូមិ ១៨
៤.៣.៣. ការពិនិត្យបេក្ខជនមេភូមិ និងការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ២៣
៤.៣.៤. កិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ ៣០
៤.៣.៥. សេចក្ដីសម្រេចតែងតាំងមេភូមិ ៣៧
**៥. ការតែងតាំងជំនួយការមេភូមិ ៤០**
៥.១. ការប្រជុំជាមួយមេភូមិដែលទើបតែងតាំងថ្មី ៤០
៥.២. ការជ្រើសរើសបេក្ខជនជំនួយការមេភូមិ ៤១
៥.៣. ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត ៤៤
៥.៤. សេចក្ដីសម្រេចតែងតាំងជំនួយការមេភូមិ ៤៥
**ឧបសម្ព័ន្ធ** : សេចក្ដីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្ដីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ៤៩





# អារម្ភកថា

យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រង់មាត្រា៣០ ចែងថា ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិមួយរូប អនុប្រធានភូមិមួយរូប និងសមាជិកភូមិមួយរូបជាជំនួយការមេភូមិ សម្រាប់ភូមិនីមួយៗចំណុះឃុំសង្កាត់របស់ខ្លួន។

យោងសេចក្ដីណែនាំ លេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្ដីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការរបស់ភូមិ។

ក្នុងគោលបំណងជួយសម្រួលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស ឱ្យដំណើរការអនុវត្តភារកិច្ចរបស់ខ្លួន ស្របតាមស្មារតីនៃសេចក្ដីណែនាំ លេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ កាន់តែមានប្រសិទ្ធភាពខ្ពស់ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ បានរៀបចំ និងចងក្រងសៀវភៅស្ដីពី**ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ** នេះឡើង។

សៀវភៅនេះ បរិយាយអំពី ÷

១). អំពីភូមិ

២). តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ភូមិ

៣). អាណត្តិការងារ និងការបាត់បង់មុខតំណែង

៤). បែបបទ និងនីតិវិធីជ្រើសរើសមេភូមិ

៥). ការតែងតាំងជំនួយការមេភូមិ

សៀវភៅនេះ មានលក្ខណៈសាមញ្ញ ងាយយល់ និងងាយប្រើប្រាស់ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ខែមេសា ឆ្នាំ២០០៦

**នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

**អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ**





# ១. អំពីភូមិ

## ១.១. និយមន័យ

☞ ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានឃុំ ឬសង្កាត់មួយ។ ភូមិមិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ ។

☞ ភូមិនីមួយៗ ត្រូវគ្រប់គ្រងដោយមេភូមិម្នាក់ អមដោយអនុប្រធានភូមិម្នាក់ និងសមាជិកភូមិម្នាក់ជាជំនួយការ ។

## ១.២. លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបំបែកភូមិ ការបង្រួមភូមិ និងការរំសាយភូមិ

☞ ដើម្បីធានាដល់ការចាត់ចែងការងារ និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចលើកសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិចំណុះឃុំ សង្កាត់របស់ខ្លួនបាន ប៉ុន្តែត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ÷

### ១.២.១. លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី

☞ ការបង្កើតភូមិថ្មី ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ ÷

- មានលំនៅដ្ឋាន និងប្រជាពលរដ្ឋយ៉ាងតិច **១៥០គ្រួសារ** ដែលប្រមូលផ្តុំគ្នា នៅទីតាំងមួយសមស្រប ហើយដែលលំបាកដាក់បញ្ចូលនៅក្នុងភូមិណាមួយនៃឃុំ សង្កាត់ជាមួយ ឬឃុំ សង្កាត់

ដែលជិតខាងជាប់គ្នា ។

- មិនត្រូវស្ថិតក្នុងទីតាំងដែលច្បាប់ហាមឃាត់ ។
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្ដាល នៃភូមិដែលគ្រោងបង្កើតថ្មីនោះគាំទ្រ ។
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ជិតខាងដែលនៅជាប់គ្នា ។

### ១.២.២. លក្ខណៈវិនិច្ឆ័យនៃការបំបែកភូមិ

☞ ការបំបែកភូមិ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ ÷

- ភូមិដែលស្នើបំបែកនោះ មានប្រជាពលរដ្ឋច្រើនលើសលប់ ឬពិបាកគ្រប់គ្រង ។
- ក្រោយពេលបំបែកហើយ នៅសល់ចំនួនប្រជាពលរដ្ឋសមស្របយ៉ាងហោចណាស់ ស្មើនឹងភូមិដែលបង្កើតថ្មីដែរ ។
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្ដាល នៃភូមិដែលស្នើសុំបំបែកនោះគាំទ្រ ។
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយជិតខាងដែលនៅជាប់គ្នា ។

### ១.២.៣. លក្ខណៈវិនិច្ឆ័យនៃការរំសាយ និងការបង្រួមភូមិបញ្ចូលគ្នា

☞ ការរំសាយ និងការបង្រួមភូមិបញ្ចូលគ្នា ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ ÷

- មានចំនួនលំនៅដ្ឋាន និងគ្រួសារប្រជាពលរដ្ឋតិចពេក ឬមានភូមិសាស្ត្ររាយប៉ាយ ពិបាកក្នុងការគ្រប់គ្រង និងការអភិវឌ្ឍ ។





- ក្រោយពេលរំសាយ និងបង្រួមបញ្ចូលគ្នាហើយ មានចំនួនប្រជាពលរដ្ឋយ៉ាងហោចណាស់ ស្មើនឹងភូមិដែលទើបបង្កើតថ្មី ។
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្ដាល នៃភូមិដែលត្រូវរំសាយ និងបង្រួមបញ្ចូលគ្នានោះគាំទ្រ ។
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយជិតខាងដែលនៅជាប់គ្នា ។

| |
|---|
| **បញ្ជាក់ :** លក្ខណសម្បត្តិខាងលើនេះ មិនត្រូវយកមកអនុវត្ត ចំពោះភូមិប្រជាពលរដ្ឋជនជាតិដើមភាគតិចឡើយ ។ |

## ១.៣. នីតិវិធីនៃការបង្កើតភូមិថ្មី ការបំបែកភូមិ ការបង្រួមភូមិ និងការរំសាយភូមិ

☞ នៅពេលដែលពិនិត្យឃើញមានតម្រូវការចាំបាច់ ក្នុងការបង្កើតភូមិថ្មី ឬការបំបែក ឬរំសាយ និងបង្រួមភូមិ មេឃុំ ចៅសង្កាត់ ត្រូវ ÷

- បង្កើតគណៈកម្មការមួយ ដើម្បីស្រាវជ្រាវ រៀបចំរបាយការណ៍ និងឯកសារផ្សេងៗ ។
- ដាក់ជូនរបាយការណ៍ និងឯកសារទាំងនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងសម្រេច ។

☞ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចឯកភាពលើសំណើសុំបង្កើតភូមិថ្មី ឬបំបែកភូមិ ឬរំសាយភូមិ និងបង្រួមបញ្ចូលគ្នានោះ មេឃុំ ចៅសង្កាត់ ត្រូវលើកសំណើទៅអភិបាលខេត្ត ក្រុងសាមី ។

☞ ក្រោយពីទទួលបានសំណើ អភិបាលខេត្ត ក្រុងត្រូវចាត់ឱ្យធ្វើការពិនិត្យ និងវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យខាងលើនេះ។ ករណីពិនិត្យឃើញថា សំណើនេះមានលក្ខណៈសមស្របហើយ អភិបាលខេត្ត ក្រុងត្រូវសុំការសម្រេចពីក្រសួងមហាផ្ទៃ។

☞ ការបង្កើតភូមិថ្មី ឬការបំបែក ឬការរំសាយ និងការបង្រួមភូមិ ត្រូវធ្វើដោយប្រកាសក្រសួងមហាផ្ទៃ។

☞ ក្នុងករណីដែលមានហេតុផលគ្រប់គ្រាន់បញ្ជាក់ថា សំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិណាមួយ ដែលមិនស្របតាមលក្ខណៈវិនិច្ឆ័យ និងមិនអនុវត្តតាមបែបបទខាងលើនេះ ក្រសួងមហាផ្ទៃ អាចបដិសេធសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិនោះ រួចហើយត្រូវណែនាំឱ្យរៀបចំសំណើជាថ្មី ឬអាចផ្អាកការបង្កើតភូមិថ្មី ឬការបំបែក ឬការរំសាយ និងបង្រួមភូមិនោះ ដោយភ្ជាប់ជាមួយនូវការណែនាំអំពីវិធានការចាំបាច់នានា ក្នុងការលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍភូមិទាំងនោះ។





# ២. តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ភូមិ

## ២.១. តួនាទី និងភារកិច្ចមេភូមិ

មេភូមិមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន។
- ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។
- បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួន មានជាអាទិ៍៖
  - ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ។
  - ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ។

- ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ អំពី ÷
  - \+ តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។
  - \+ ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងភូមិរបស់ខ្លួន ។
  - \+ ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។

- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ត្រូវធានាផ្តល់ព័ត៌មានជាឯកសារជាសាធារណៈ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័ត៌មានទាំងនោះអាចរួមមាន ព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ។
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។





**បញ្ជាក់ :**

☞ មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ ។

☞ មេភូមិ ពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានឡើយ ។

☞ ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយ នៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ២.២. តួនាទី និងភារកិច្ចជំនួយការមេភូមិ

ជំនួយការមេភូមិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- **អនុប្រធានភូមិ** ទទួលជំនួសមេភូមិ ក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជា មានជម្ងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួន លើសពី១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិ ត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិ តាមគម្រោងផែនការរបស់ឃុំ សង្កាត់ ។

- **សមាជិកភូមិ** ទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

**បញ្ជាក់ :** ក្រៅពីការងារខាងលើនេះ មេភូមិអាចធ្វើការបែងចែក ប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្ដីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី។

## ២.៣. របៀបរបបការងាររបស់ភូមិ

☞ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវ ÷

- ជួបប្រជុំគ្នាយ៉ាងតិច មួយដងក្នុងមួយខែ។
- ធ្វើការពិគ្រោះយោបល់ឱ្យបានទៀងទាត់ ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។
- មានវត្តមាននៅទីកន្លែងដែលបានកំណត់ ដើម្បីជួបប្រជាពលរដ្ឋ។

☞ ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចនឹងជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់។





## ២.៤. ទីកន្លែងធ្វើការងារ

☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំឱ្យមានទីកន្លែង សម្រាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ។

☞ ទីកន្លែងធ្វើការងារនោះ អាចជាទីស្នាក់ការភូមិ ចំពោះភូមិដែលមានទីស្នាក់ការ ។ ចំពោះភូមិដែលគ្មានទីស្នាក់ការ ត្រូវពិគ្រោះពិភាក្សាគ្នា ដើម្បីរកទីកន្លែងសមស្របណាមួយ ដែលអាចជា ÷

- សាលារៀន
- វត្តអារាម
- វិហារសាសនា
- អគារសាធារណៈ ឬ
- គេហដ្ឋានផ្ទាល់របស់មេភូមិ។

☞ ការជ្រើសរើសយកទីកន្លែងណាមួយ ត្រូវមានការពិគ្រោះពិភាក្សាឱ្យឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ហើយត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ។

☞ មេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយអំពីទីកន្លែងធ្វើការងារនោះដល់សាធារណជន។

☞ ទីកន្លែងធ្វើការងាររបស់ភូមិ ត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់**មួយថ្ងៃ ក្នុងមួយសប្ដាហ៍**។

# ៣. អាណត្តិការងារ និងការបាត់បង់មុខតំណែង

## ៣.១. អាណត្តិការងារ

☞ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ ។

☞ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែង ត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស ។

## ៣.២. លក្ខខណ្ឌនានានៃការបាត់បង់មុខតំណែង

☞ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយ ដូចខាងក្រោម ÷

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាលាយល័ក្ខណ៍អក្សរ
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីភ្នាក់ងារមានសមត្ថកិច្ច
- សាមីខ្លួនត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់របស់ខ្លួន
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ





- សាមីខ្លួនផ្លាស់ទីលំនៅទៅភូមិផ្សេង
- សាមីខ្លួនមានកំហុសឆ្គងក្នុងការងារ ហើយត្រូវបញ្ឈប់ពីមុខតំណែង ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

☞ មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលអនុវត្តផ្ទុយពីតួនាទីភារកិច្ច និងរបៀបរបបការងារ ដូចមានចែងនៅក្នុងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពី**បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ** ត្រូវចាត់ទុកថា មានកំហុសឆ្គងក្នុងការងារ ។

## ៣.៣. នីតិវិធីក្នុងការបញ្ឈប់ពីមុខតំណែង

☞ ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាមួយដែលបានប្រព្រឹត្តខុសឆ្គងក្នុងការងារ មេឃុំ ចៅសង្កាត់សាមី ត្រូវធ្វើការណែនាំជាលាយល័ក្ខណ៍អក្សរឱ្យសាមីខ្លួន កែលំអចំណុចខុសឆ្គងទាំងនោះ និងត្រូវធ្វើសេចក្តីរាយការណ៍ជូនក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

☞ ក្នុងករណីដែលបានទទួលការណែនាំហើយ ប៉ុន្តែសាមីខ្លួននៅតែប្រព្រឹត្តខុសឆ្គងបន្តទៀតនោះ មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ

កោះអញ្ជើញសាមីខ្លួនឱ្យមកទទួលការណែនាំ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យសាមីខ្លួនធ្វើការកែលំអកំហុសឆ្គង ។

☞ ក្រោយពីបានទទួលការណែនាំពីក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ ប្រសិនបើសាមីខ្លួនមិនព្រមរាងចាល មេឃុំ ចៅសង្កាត់ ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្នើសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សម្រេច អនុម័តបញ្ឈប់ជននោះពីមុខតំណែង តាមសម្លេងភាគច្រើនលើសពីពាក់កណ្តាលនៃក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

☞ ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាម្នាក់ត្រូវបានបាត់បង់ពីមុខតំណែងតាមករណីណាមួយខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យធ្វើការជ្រើសរើសបេក្ខជនសម្រាប់កន្លែងដែលទំនេរនោះ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ អនុម័តក្នុងរយៈពេល**០៧ថ្ងៃ**យ៉ាងយូរ ស្របទៅតាមបែបបទ និងនីតិវិធី ដូចមានចែង នៅក្នុងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពី**បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ**។





# ៤. បែបបទ និងនីតិវិធី នៃការជ្រើសរើសមេភូមិ

អនុលោមតាមមាត្រា៣០ និងមាត្រា៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី១នេះ ត្រូវធ្វើការជ្រើសរើសមេភូមិនៅគ្រប់ភូមិទាំងអស់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## ៤.១. ភូមិដែលត្រូវជ្រើសរើសមេភូមិ

☞ ការរៀបចំជ្រើសរើសមេភូមិ ត្រូវធ្វើឡើងតែនៅភូមិណា ដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។

☞ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួនធ្វើសេចក្តីរាយការណ៍អំពីឈ្មោះភូមិ ដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។

## ៤.២. លក្ខណសម្បត្តិនៃបេក្ខជនមេភូមិ

☞ បេក្ខជនមេភូមិ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ÷

- មានសញ្ជាតិខ្មែរ

- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននោះយ៉ាងតិច ០៦ខែជាប់ៗគ្នា។

## ៤.៣. នីតិវិធីជ្រើសរើសមេភូមិ

☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការជ្រើសរើសមេភូមិ សម្រាប់ភូមិនីមួយៗ តាមនីតិវិធី ដូចខាងក្រោម ÷

- ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- ការជ្រើសរើសបេក្ខជនមេភូមិ
- ការពិនិត្យបេក្ខជនមេភូមិ និងការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ
- កិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ
- សេចក្តីសម្រេចតែងតាំងមេភូមិ





### ៤.៣.១. ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

☞ មុននឹងដំណើរការជ្រើសរើសមេភូមិ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ដែលមានរបៀបវារៈដូចតទៅ ÷

- រាយការណ៍អំពីភូមិដែលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ
- ណែនាំអំពីនីតិវិធីដាក់ស្នើបេក្ខជនមេភូមិ
- កាលវិភាគនៃដំណើរការជ្រើសរើសមេភូមិ

☞ មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អំពីឈ្មោះភូមិដែលក្រសួងមហាផ្ទៃទទួលស្គាល់។

☞ អធិបតីអង្គប្រជុំ ត្រូវណែនាំដល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងអំពីនីតិវិធីនៃការដាក់ស្នើបេក្ខជនមេភូមិ។

☞ អង្គប្រជុំក៏ត្រូវឯកភាពគ្នាផងដែរ ទៅលើកាលវិភាគនៃដំណើរការជ្រើសរើសមេភូមិ ដូចតទៅ ÷

- កាលបរិច្ឆេទនៃការដាក់ស្នើបេក្ខជនមេភូមិ។
- កាលបរិច្ឆេទនៃការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យបេក្ខជនមេភូមិ និងបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ។
- កាលបរិច្ឆេទនៃការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបោះឆ្នោតជ្រើសរើសមេភូមិ។

**បញ្ជាក់ :**

- ☞ ស្មៀនឃុំ សង្កាត់ ត្រូវរៀបចំកំណត់ហេតុនៃគ្រប់ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ នៅក្នុងដំណើរការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ។
- ☞ គ្រប់កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ នៅក្នុងដំណើរការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ ត្រូវអនុម័តភ្លាម បន្ទាប់ពីការប្រជុំនីមួយៗ។
- ☞ ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងដំណើរការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ គឺជាការប្រជុំសាធារណៈ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយអំពីការប្រជុំទាំងនេះ ដល់ប្រជាពលរដ្ឋ។

## ៤.៣.២. ការជ្រើសរើសបេក្ខជនមេភូមិ

- ☞ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងរបស់ខ្លួន រៀបចំជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិច ០៣រូប សម្រាប់ភូមិនីមួយៗ ក្នុងឃុំ សង្កាត់របស់ខ្លួន។
- ☞ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ម្នាក់ៗ ត្រូវជ្រើសរើសបេក្ខជនមេភូមិ យ៉ាងតិចចំនួន ០១រូប ក្នុងមួយភូមិ ដែលមានលក្ខណសម្បត្តិដូចចំណុច ៤.២ និងដែលខ្លួនទុកចិត្ត នៅគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់របស់ខ្លួន។





- ☞ បើក្នុងចំណោមមេឃុំចៅសង្កាត់ ជំទប់ទី១ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ មានអ្នកណាម្នាក់មិនដាក់ស្នើបេក្ខជនមេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវ ÷
  - ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសមេភូមិ បើបេក្ខជនមេភូមិដែលបានស្នើ មានចំនួនយ៉ាងតិច៣រូបសម្រាប់មួយភូមិ។
  - ស្នើឱ្យមេឃុំ ចៅសង្កាត់ ឬជំទប់ទី១ ចៅសង្កាត់រងទី១ ឬជំទប់ទី២ ចៅសង្កាត់រងទី២ណាដែលបានដាក់ស្នើបេក្ខជនមេភូមិ ធ្វើការដាក់ស្នើបេក្ខជនមេភូមិបន្ថែម ដើម្បីឱ្យចំនួនបេក្ខជនមេភូមិសម្រាប់មួយភូមិ មានចំនួនយ៉ាងតិច០៣រូប បើបេក្ខជនមេភូមិដែលបានស្នើ មានចំនួនតិចជាង៣រូប សម្រាប់មួយភូមិ។
- ☞ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវពិគ្រោះពិភាក្សាគ្នាខិតខំជ្រើសរើស ឱ្យមានស្ត្រីសម្រាប់ជាបេក្ខជនមេភូមិ នៅគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់របស់ខ្លួន។
- ☞ បន្ទាប់ពីជ្រើសរើសបានបេក្ខជនហើយ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ត្រូវធ្វើលិខិតស្នើសុំដាក់បេក្ខជនមេភូមិទាំងនោះ រៀងៗខ្លួន ទៅប្រធានក្រុមប្រឹក្សាឃុំសង្កាត់ជាលាយល័ក្ខណ៍អក្សរ ដើម្បីរៀបចំការបោះឆ្នោត ដោយភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេបរបស់បេក្ខជនមេភូមិ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ........................ ជា........................ នៃឃុំ សង្កាត់........................។

**គោរពជូន**

**លោក លោកស្រីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់....................**

**<u>កម្មវត្ថុ</u> :** សំណើសុំដាក់បេក្ខជនមេភូមិ សម្រាប់ភូមិ...................................... ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ មានកិត្តិយស សូមជម្រាបជូនលោក លោកស្រីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មេត្តាជ្រាបថា លោក លោកស្រីដែល មានឈ្មោះខាងក្រោមនេះ ពិតជាមានលក្ខណសម្បត្តិគ្រប់គ្រាន់ ជាបេក្ខជនមេភូមិ......................... ។

១). ............(ឈ្មោះ)............. ភេទ.......... អាយុ..........ឆ្នាំ

២). ............(ឈ្មោះ)............. ភេទ.......... អាយុ..........ឆ្នាំ

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មេត្តារៀបចំប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបោះឆ្នោតជ្រើសរើសមេភូមិ ដោយសេចក្តីអនុគ្រោះ។

សូមលោក លោកស្រីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំបាទ នាងខ្ញុំ ។

ថ្ងៃទី----- ខែ---------- ឆ្នាំ-------

**អ្នកស្នើ**

(ហត្ថលេខា និងឈ្មោះ)

បានទទួល

នៅថ្ងៃទី........ ខែ.......... ឆ្នាំ...........

វេលាម៉ោង......................។

**អ្នកទទួល**

(ហត្ថលេខា និងឈ្មោះ)





**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រវត្តិរូបសង្ខេប**

១. ឈ្មោះ................................................ ភេទ.............. សញ្ជាតិ.............. ។

២. ថ្ងៃខែឆ្នាំកំណើត : កើតនៅថ្ងៃទី.............. ខែ..................... ឆ្នាំ................. ។

៣. ទីកន្លែងកំណើត : ភូមិ............... ឃុំសង្កាត់................. ស្រុកខណ្ឌ................. ខេត្តក្រុង...............។

៤. អាសយដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ.......... ផ្លូវ............. នៅភូមិ..................... ឃុំសង្កាត់.......................
ស្រុកខណ្ឌ................. ខេត្តក្រុង..................... ។ ទូរស័ព្ទសម្រាប់ទំនាក់ទំនងលេខ........................។

៥. ស្ថានភាពគ្រួសារ : នៅលីវ ☐ មានប្រពន្ធ-ប្តី ☐ ពោះម៉ាយ-មេម៉ាយ ☐

ក). ប្រពន្ធ-ប្តី : ឈ្មោះ........................................ ថ្ងៃខែឆ្នាំកំណើត.........................................
មុខរបរ.........................................................................................................

ខ). ចំនួនកូន.............នាក់ ស្រី...........នាក់ ប្រុស............នាក់ ។

៦. ការសិក្សា :

ក). កម្រិតវប្បធម៌ទូទៅ :.........................................................................................

ខ). កម្រិតជំនាញ និងការបណ្តុះបណ្តាលផ្សេងៗ :

.........................................................................................................

.........................................................................................................

.........................................................................................................

៧. មុខងារ និងទីកន្លែងដែលធ្លាប់បម្រើការងារ :

.........................................................................................................

.........................................................................................................

.........................................................................................................

.........................................................................................................

.........................................................................................................

៨. ខ្ញុំសូមអះអាងចំពោះមុខច្បាប់ថា សេចក្តីរាយការណ៍នេះ សុទ្ធតែជាការពិតទាំងអស់ ។

ថ្ងៃទី........ ខែ.............. ឆ្នាំ..........

**ហត្ថលេខាសាមីខ្លួន**

**បញ្ជាក់ :**

- ☞ បើដល់ពេលកំណត់ហើយ បេក្ខជនមេភូមិដែលបានដាក់ស្នើ មានចំនួនតិចជាង០៣រូបក្នុងមួយភូមិ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវស្នើឱ្យមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងណាដែលបានដាក់ស្នើបេក្ខជនមេភូមិ ធ្វើការដាក់ស្នើបេក្ខជនមេភូមិបន្ថែម ដើម្បីឱ្យចំនួនបេក្ខជនមេភូមិ សម្រាប់មួយភូមិ មានចំនួនយ៉ាងតិច០៣រូប ។
- ☞ ជាការប្រសើរ ក្រុមប្រឹក្សាឃុំ សង្កាត់ គួរណែនាំឱ្យមេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ដាក់ស្នើបេក្ខជនមេភូមិរបស់ខ្លួន ឱ្យបានក្នុងពេលដំណាលគ្នា ។
- ☞ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ត្រូវរៀបចំលិខិតស្នើសុំដាក់បេក្ខជនមេភូមិ មួយភូមិៗ ដាច់ដោយឡែកពីគ្នា រៀងៗខ្លួន ក្នុងអំឡុងពេលយ៉ាងយូរ**៥ថ្ងៃ** បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ស្ដីពីការរាយការណ៍ឈ្មោះភូមិដែលក្រសួងមហាផ្ទៃ ទទួលស្គាល់ និងការណែនាំអំពីនីតិវិធីដាក់ស្នើបេក្ខជនមេភូមិ ។
- ☞ មេឃុំ ចៅសង្កាត់ ត្រូវចាត់ឱ្យមានអ្នកទទួល (អាចជាស្មៀនឃុំ សង្កាត់) សំណើសុំដាក់បេក្ខជនមេភូមិរបស់មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ។ នៅពេលទទួលបានសំណើសុំដាក់បេក្ខជនមេភូមិ ត្រូវកត់ត្រានៅក្នុងលិខិតចូលរបស់ឃុំ សង្កាត់ ។





## ៤.៣.៣. ការពិនិត្យបេក្ខជនមេភូមិ និងការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ

- ☞ បន្ទាប់ពីទទួលបានសំណើសុំដាក់បេក្ខជនមេភូមិពីមេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បី ÷
  - ពិនិត្យបេក្ខជនមេភូមិ និង
  - រៀបចំអនុម័តបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ
- ☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការពិនិត្យបេក្ខជនមេភូមិដែលបានដាក់ស្នើដោយមេឃុំ ចៅសង្កាត់ និងជំទប់ ចៅសង្កាត់រង ម្ដងមួយភូមិៗ ថាតើបេក្ខជនមេភូមិទាំងនោះមានលក្ខណសម្បត្តិសមស្រប ដូចបានកំណត់ នៅចំណុច ៤.២ ដែរឬទេ ។
- ☞ គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ មានសមាសភាព ០៣រូប ដូចខាងក្រោម ÷
  - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ០១រូប ជាប្រធាន
  - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ០១រូប ជាសមាជិក
  - ស្មៀនឃុំ សង្កាត់ ជាសមាជិក
- ☞ គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ មានភារកិច្ច ÷
  - រៀបចំសន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗនៃភូមិទាំងអស់ នៅក្នុងឃុំសង្កាត់ ។

- រៀបចំ និងអនុវត្តកិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិគ្រប់ភូមិទាំងអស់ នៅក្នុងឃុំ សង្កាត់ ។

☞ សន្លឹកឆ្នោតនៃភូមិនីមួយៗត្រូវ ÷

- ប្រើក្រដាសពណ៌ស ដែលមានទម្រង់ ទំហំដូចគ្នា ដោយសរសេរឈ្មោះបេក្ខជន ទៅតាមលំដាប់អក្សរនៃឈ្មោះរបស់បេក្ខជន (សរសេរដោយដៃ ឬម៉ាស៊ីនអង្គុលីលេខ ឬកុំព្យូទ័រ) ។
- រៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។
- មានត្រារបស់ឃុំ សង្កាត់ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត ។

**បញ្ជាក់ :**

☞ ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ត្រូវធ្វើឡើងយ៉ាងយូរបំផុត **នៅថ្ងៃទី៦** បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីការរាយការណ៍ឈ្មោះភូមិដែលក្រសួងមហាផ្ទៃទទួលស្គាល់ និងការណែនាំអំពីនីតិវិធីដាក់ស្នើបេក្ខជនមេភូមិ ។

☞ មេឃុំ ចៅសង្កាត់ ត្រូវចេញសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ។

☞ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគូសសញ្ញា "✓" នៅលើសន្លឹកឆ្នោត ត្រង់កូឡោន "**ការបោះឆ្នោតគាំទ្រ**" នៅជួរបន្ទាត់នៃឈ្មោះបេក្ខជនមេភូមិតែម្នាក់ប៉ុណ្ណោះដែលខ្លួនគាំទ្រ ។





## គំរូសន្លឹកឆ្នោត








៤. បែបបទ និងនីតិវិធីនៃការជ្រើសរើសមេភូមិ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង :............

ស្រុក ខណ្ឌ :............

ឃុំ សង្កាត់ :............

លេខ :.......ស.ស.រ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ**

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពី បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ។
- យោងកំណត់ហេតុអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នាថ្ងៃទី....... ខែ........... ឆ្នាំ........ ស្តីពីការបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ។

**ស ម្រ េ ច**

**ប្រការ ១ ..**

បង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ដែលមានសមាសភាព ដូចខាងក្រោម ÷

១. .................................... ...........(តួនាទី)........ ជាប្រធាន

២. .................................... ...........(តួនាទី)........ ជាសមាជិក

៣. .................................... ...........(តួនាទី)........ ជាសមាជិក





**ប្រការ ២ ..**

គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំសន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗនៃភូមិទាំងអស់ នៅក្នុង ឃុំសង្កាត់ ។
- រៀបចំ និងអនុវត្តកិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិគ្រប់ភូមិទាំងអស់ នៅក្នុងឃុំ សង្កាត់ ។

**ប្រការ ៣ ..**

គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី...... ខែ............ ឆ្នាំ......

**មេឃុំ ចៅសង្កាត់**

(ហត្ថលេខា)

(ត្រា)

(ឈ្មោះហត្ថលេខី)

**<u>ចម្លងជូន</u>**

- សាលាខេត្ត ក្រុង..................
- សាលាស្រុក ខណ្ឌ................

*"ដើម្បីជូនជ្រាប"*

- ដូចក្នុងប្រការ១

*"ដើម្បីអនុវត្ត"*

- ឯកសារ កាលប្បវត្តិ

## ៤.៣.៤. កិច្ចដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ

☞ បន្ទាប់ពីបានរៀបចំសន្លឹកឆ្នោតតាមភូមិនីមួយៗ គ្រប់ភូមិទាំងអស់ក្នុងឃុំ សង្កាត់របស់ខ្លួនរួចហើយ គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ត្រូវដាក់សន្លឹកឆ្នោតទាំងនោះជូនមេឃុំ ចៅសង្កាត់ពិនិត្យ ។

☞ ក្រោយពីពិនិត្យឃើញថា សន្លឹកឆ្នោតទាំងនោះមានភាពត្រឹមត្រូវហើយ មេឃុំ ចៅសង្កាត់ដែលជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំការបោះឆ្នោត ក្នុងរយៈពេល**៧ថ្ងៃ** បន្ទាប់ពីថ្ងៃដាក់ស្នើបេក្ខជននោះ ។

☞ មុននឹងដំណើរការបោះឆ្នោតជ្រើសរើសមេភូមិ អធិបតីនៃអង្គប្រជុំដែលជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជម្រាបជូនអង្គប្រជុំអំពីគោលការណ៍សំខាន់ៗ ដូចខាងក្រោម ÷

- សន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ សន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យដូចៗគ្នានូវទម្រង់ ទំហំ និងឈ្មោះបេក្ខជន ។
- សមាជិកក្រុមប្រឹក្សាម្នាក់ៗ មានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយសន្លឹកសម្រាប់ភូមិមួយ ដែលបានចែកជូនក្នុងពេលបោះឆ្នោត ។
- សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវគូសជ្រើសយកបេក្ខជនដែលខ្លួនគាំទ្រតែម្នាក់ប៉ុណ្ណោះ លើសន្លឹកឆ្នោតដែលបានចែកជូន ដោយគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ។





- សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល ÷
  - មិនមែនជាសន្លឹកឆ្នោត ដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ
  - គ្មានត្រារបស់ឃុំ សង្កាត់
  - គូសគាំទ្របេក្ខជនលើសពីម្នាក់
  - មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
  - មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត
  - រហែក ឬខូច
  - មានគំនូស តែគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសមេភូមិ មិនអាចកំណត់បានថា គាំទ្របេក្ខជនណាមួយ ។

☞ បន្ទាប់ពីណែនាំរួចហើយ អធិបតីនៃអង្គប្រជុំត្រូវប្រគល់កម្មវិធីជូនគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ដើម្បីរៀបចំបោះឆ្នោតម្តងមួយភូមិៗ ។ ប្រធានគណៈកម្មការបោះឆ្នោត ត្រូវ ÷

- ជម្រាបជូនអង្គប្រជុំថា "**ការបោះឆ្នោតនេះ គឺជាការបោះឆ្នោតសម្ងាត់**"
- បង្ហាញ និងណែនាំអំពីលក្ខណៈនៃសន្លឹកឆ្នោត ÷
  - ខាងមុខ មានសរសេរអក្សរថា "**សន្លឹកឆ្នោត**"
  - ខាងក្នុង មានបញ្ជីឈ្មោះបេក្ខជនមេភូមិ
  - ខាងក្រោយ មានត្រាឃុំ សង្កាត់

- ណែនាំអំពីរបៀបគូសសន្លឹកឆ្នោត ៖ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគូសសញ្ញា "✓" នៅលើសន្លឹកឆ្នោត ត្រង់កូឡោន "**ការបោះឆ្នោតគាំទ្រ**" នៅជួរបន្ទាត់នៃឈ្មោះបេក្ខជនមេភូមិតែម្នាក់ប៉ុណ្ណោះដែលខ្លួនគាំទ្រ។
- បន្ទាប់ពីគូសសន្លឹកឆ្នោតរួច ត្រូវយកមកដាក់ក្នុងហិបឆ្នោត។

☞ គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ អនុវត្តដំណើរការបោះឆ្នោតម្តងមួយភូមិៗ ដូចតទៅ ÷

- ប្រធានគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ អានឈ្មោះបេក្ខជនមេភូមិជូនអង្គប្រជុំ
- ចែកសន្លឹកឆ្នោតជូនសមាជិកក្រុមប្រឹក្សា ដែលមានវត្តមានក្នុងកិច្ចប្រជុំ ម្នាក់មួយសន្លឹក ដើម្បីបោះឆ្នោតជ្រើសរើសមេភូមិ។
- ទុកពេលវេលាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការបោះឆ្នោត និងដាក់សន្លឹកឆ្នោតដែលបានគូសរួចទៅក្នុងហិបឆ្នោត។
- យកសន្លឹកឆ្នោតចេញពីហិបឆ្នោត បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បានដាក់សន្លឹកឆ្នោតរបស់ខ្លួនទៅក្នុងហិបឆ្នោតគ្រប់ៗគ្នា។
- រាប់សន្លឹកឆ្នោតដែលបានបោះហើយ នៅចំពោះមុខអង្គប្រជុំ។
- ពិនិត្យសន្លឹកឆ្នោត និងកត់ត្រាលទ្ធផលនៃការបោះឆ្នោត ដោយធ្វើការបែងចែកការងារ ក្នុងគណៈកម្មការ ដូចខាងក្រោម ÷





  - ប្រធានគណៈកម្មការ ពិនិត្យសន្លឹកឆ្នោត អានឈ្មោះបេក្ខជនមេភូមិដែលបានទទួលការបោះឆ្នោតគាំទ្រ និងបង្ហាញសន្លឹកឆ្នោតនោះ ដល់អង្គប្រជុំ។
  - សមាជិកគណៈកម្មការដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កត់ត្រាលទ្ធផលនៃការបោះឆ្នោត នៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ
  - សមាជិកគណៈកម្មការដែលជាស្មៀនឃុំ សង្កាត់ ធ្វើកំណត់ហេតុ។

- បន្ទាប់មក ប្រធានគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ត្រូវរាយការណ៍ជូនអង្គប្រជុំ ដូចខាងក្រោម ÷
  - សន្លឹកឆ្នោតដែលបានបោះសរុបចំនួន ...........សន្លឹក
  - សន្លឹកឆ្នោតបានការចំនួន ............សន្លឹក
  - សន្លឹកឆ្នោតមិនបានការចំនួន ............សន្លឹក
  - លទ្ធផលមានដូចតទៅ ÷
    + លោក ឬលោកស្រី.............. បាន..........សម្លេង
    + លោក ឬលោកស្រី............... បាន..........សម្លេង
    + លោក ឬលោកស្រី.............. បាន..........សម្លេង

## លទ្ធផលនៃការបោះឆ្នោតមេភូមិ..................

| ល.រ | ឈ្មោះបេក្ខជន | ភេទ | អាយុ | សម្លេងគាំទ្រ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

**បញ្ជាក់ :** សមាជិកគណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ត្រូវបោះឆ្នោតជ្រើសរើសមេភូមិ ដូចសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀតដែរ ។

☞ អធិបតីនៃអង្គប្រជុំត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោតហើយភ្លាម ។

☞ បន្ទាប់មកអធិបតីនៃអង្គប្រជុំ ត្រូវចាត់ឱ្យគណៈកម្មការបោះឆ្នោតរៀបចំបោះឆ្នោតជ្រើសរើសមេភូមិផ្សេងទៀត ដែលនៅសល់ជាបន្តបន្ទាប់រហូតគ្រប់ចំនួនភូមិ ដែលបានទទួលស្គាល់ជាផ្លូវការ ។

☞ បេក្ខជនដែលជាប់ឆ្នោត គឺជាបេក្ខជនដែលមានសម្លេងឆ្នោតគាំទ្រច្រើនជាងគេ ហើយសម្លេងគាំទ្រនោះ ត្រូវមានចំនួន**លើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល**។





| សម្លេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល មានដូចខាងក្រោម÷ | |
|---|---|
| ចំនួនក្រុមប្រឹក្សា | ចំនួនសម្លេងលើសពីពាក់កណ្តាល |
| • ៥ រូប | • ៣ សម្លេងយ៉ាងតិច |
| • ៧ រូប | • ៤ សម្លេងយ៉ាងតិច |
| • ៩ រូប | • ៥ សម្លេងយ៉ាងតិច |
| • ១១ រូប | • ៦ សម្លេងយ៉ាងតិច |

☞ ក្នុងករណីបេក្ខជនណាដែលមានសម្លេងឆ្នោតស្មើគ្នា ÷

- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះ សុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។
- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះ ម្នាក់ជាបុរស និងម្នាក់ជាស្ត្រី បេក្ខជនស្ត្រីត្រូវបានជាប់ឆ្នោតជាមេភូមិ ។

☞ ចំពោះបេក្ខជនភូមិណា ដែលមិនបានទទួលសម្លេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល អង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ដាក់ស្នើបេក្ខជនជាថ្មី និងដំណើរការបោះឆ្នោតជាថ្មី សម្រាប់ភូមិនោះ ទៅតាមបែបបទ នីតិវិធី ដូចបានរៀបរាប់ខាងលើ ។

☞ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសបេក្ខជនមេភូមិនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ **០៧ថ្ងៃ** បន្ទាប់ពីថ្ងៃបោះឆ្នោតលើកទី១។

☞ នៅក្នុងការបោះឆ្នោតលើកទី២នេះ ប្រសិនបើបេក្ខជននៅតែមិនបានទទួលសម្លេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូលទៀត អង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ជ្រើសយកតែបេក្ខជនពីររូប ដែលមានសម្លេងឆ្នោតគាំទ្របន្តបន្ទាប់គ្នា មកធ្វើការបោះឆ្នោតជ្រើសរើសសាឡើងវិញភ្លាម។

☞ បន្ទាប់ពីជ្រើសរើសបានបេក្ខជនពីររូប ដែលមានសម្លេងឆ្នោតគាំទ្របន្តបន្ទាប់គ្នារួចមក គណៈកម្មការបោះឆ្នោតជ្រើសរើសមេភូមិ ត្រូវរៀបចំសន្លឹកឆ្នោត និងអនុវត្តដំណើរការបោះឆ្នោត ដូចដំណើរការបោះឆ្នោតលើកទី១ និងលើកទី២ដែរ។

☞ ក្នុងការបោះឆ្នោតសាឡើងវិញភ្លាមនេះ បើនៅតែមិនមានបេក្ខជនណាម្នាក់ដែលបានទទួលសម្លេងគាំទ្រ លើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសម្រេចជ្រើសរើស នៅក្នុងអង្គប្រជុំ÷

- សម្រេចជ្រើសយកបេក្ខជនជាស្ត្រីធ្វើជាមេភូមិ បើក្នុងចំណោមបេក្ខជនទាំងពីរខាងលើនេះ មានម្នាក់ជាស្ត្រី





- សម្រេចជ្រើសយកបេក្ខជនដែលមានអាយុចាស់ជាងធ្វើជាមេភូមិ បើបេក្ខជនទាំងពីរខាងលើនេះ សុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី។

## ៤.៣.៥. សេចក្តីសម្រេចតែងតាំងមេភូមិ

☞ បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បោះឆ្នោតជ្រើសរើសបានមេភូមិរួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចតែងតាំងមេភូមិទាំងនោះ ក្នុងរយៈពេល**០៧ថ្ងៃ**យ៉ាងយូរ បន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោតគាំទ្រ។

**បញ្ជាក់ :**

☞ មេឃុំ ចៅសង្កាត់ ត្រូវចេញសេចក្តីសម្រេចតែងតាំងមេភូមិទាំងនោះមួយភូមិៗ ដាច់ដោយឡែកពីគ្នា។ សេចក្តីសម្រេចនេះ ត្រូវចុះកាលបរិច្ឆេទតាមជាក់ស្តែង និងចុះលេខផ្សេងៗគ្នា។

☞ ជាការប្រសើរ មេឃុំ ចៅសង្កាត់ គួរចេញសេចក្តីសម្រេចតែងតាំងមេភូមិនៃភូមិទាំងអស់ នៅក្នុងឃុំ សង្កាត់របស់ខ្លួន ក្នុងថ្ងៃតែមួយ។

☞ សេចក្តីសម្រេចតែងតាំងមេភូមិ និងជំនួយការមេភូមិ ត្រូវផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នៅក្នុងភូមិ ដោយការបិទផ្សាយជាសាធារណៈ តាមមធ្យោបាយផ្សេងៗ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង :------------

ស្រុក ខណ្ឌ :------------

ឃុំ សង្កាត់ :------------

លេខ :--------ស.ស.រ

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងមេភូមិ**--------(ឈ្មោះភូមិ)----------

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឍការអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពី បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ។
- យោងកំណត់ហេតុអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នាថ្ងៃទី....... ខែ............ ឆ្នាំ........ ស្តីពីការបោះឆ្នោតជ្រើសរើសមេភូមិ ។

**ស ម្រេ ច**

**ប្រការ ១ ..**

ត្រូវបានតែងតាំង............(លោក ឬលោកស្រី ឬកញ្ញាឈ្មោះ)............ ជាមេភូមិ.......................... ។

**ប្រការ ២ ..**

មេភូមិ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ទទួលខុសត្រូវកិច្ចការរួមក្នុងភូមិរបស់ខ្លួន ។
- ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិរបស់ខ្លួន និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។





- បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួន មានជាអាទិ៍ ÷
  - ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ ។
  - ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ ។
  - ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ អំពី ÷
    - \+ តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។
    - \+ ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។
    - \+ ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។
- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ត្រូវធានាផ្តល់ព័ត៌មានជាឯកសារជាសាធារណៈ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័ត៌មាន ទាំងនោះអាចរួមមាន ព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ។
- អនុវត្តកិច្ចការផ្សេងៗទៀតដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

**ប្រការ ៣ ..**

មេភូមិ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី------ ខែ------------ ឆ្នាំ------

**មេឃុំ ចៅសង្កាត់**

(ហត្ថលេខា)

(ត្រា)

(ឈ្មោះហត្ថលេខី)

**<u>ចម្លងជូន</u>**

- សាលាខេត្ត ក្រុង..................
- សាលាស្រុក ខណ្ឌ..................
  *"ដើម្បីជូនជ្រាប"*
- សាមីខ្លួន *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ

# ៥. ការតែងតាំងជំនួយការមេភូមិ

អនុលោមតាមមាត្រា៣០ និងមាត្រា៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវណែនាំមេភូមិនីមួយៗ ដែលបានទទួលការតែងតាំងជាផ្លូវការរួចហើយនោះ ឱ្យធ្វើការដាក់បេក្ខជនជំនួយការរបស់ខ្លួន ជាអនុប្រធាន និងសមាជិកភូមិ រួចហើយលើកសំណើដល់មេឃុំ ចៅសង្កាត់សាមី ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ពិនិត្យ និងអនុម័តក្នុងរយៈពេលយ៉ាងយូរ**០៧ថ្ងៃ** បន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះជាផ្លូវការ ។

ការជ្រើសរើសជំនួយការមេភូមិ សម្រាប់ភូមិនីមួយៗ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម ÷

- ការប្រជុំជាមួយមេភូមិដែលទើបតែងតាំងថ្មី
- ការជ្រើសរើសបេក្ខជនជំនួយការមេភូមិ
- ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត
- សេចក្តីសម្រេចតែងតាំង

## ៥.១. ការប្រជុំជាមួយមេភូមិដែលទើបតែងតាំងថ្មី

☞ បន្ទាប់ពីការតែងតាំងមេភូមិរួច មេឃុំ ចៅសង្កាត់ត្រូវរៀបចំការប្រជុំមួយជាមួយនឹងមេភូមិដែលទើបនឹងតែងតាំងថ្មីទាំងនោះ ដើម្បី ÷

- ណែនាំអំពីនីតិវិធីនៃការដាក់ស្នើបេក្ខជនជំនួយការមេភូមិ
- កំណត់កាលបរិច្ឆេទដាក់សំណើបេក្ខជនជំនួយការមេភូមិ ។





## ៥.២. ការជ្រើសរើសបេក្ខជនជំនួយការមេភូមិ

☞ មេភូមិនីមួយៗ ដែលបានទទួលការតែងតាំងជាផ្លូវការរួចហើយ ត្រូវធ្វើការជ្រើសរើសបេក្ខជនជំនួយការរបស់ខ្លួន ជាអនុប្រធាន និងសមាជិកភូមិ ក្នុងរយៈពេលយ៉ាងយូរ**០៧ថ្ងៃ** បន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះ ជាផ្លូវការ ។

☞ លក្ខណសម្បត្តិនៃបេក្ខជនជំនួយការមេភូមិ មានដូចតទៅ ÷

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
-ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននោះ យ៉ាងតិច ០៦ខែជាប់ៗគ្នា ។

☞ បេក្ខជនជំនួយការមេភូមិ (អនុប្រធានភូមិ និងសមាជិកភូមិ) នៃភូមិនីមួយៗ យ៉ាងតិចណាស់ ត្រូវមានបេក្ខជនជាស្ត្រីម្នាក់ សម្រាប់មុខតំណែងអនុប្រធានភូមិ ឬសមាជិកភូមិ ចំពោះភូមិទាំងឡាយណាដែលមានមេភូមិជាបុរស ។

☞ បន្ទាប់ពីជ្រើសរើសបេក្ខជនរួច មេភូមិត្រូវធ្វើលិខិតស្នើសុំដាក់បេក្ខជនទាំងនោះទៅមេឃុំ ចៅសង្កាត់របស់ខ្លួន ជាលាយល័ក្ខណ៍អក្សរ ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបរបស់បេក្ខជនជំនួយការមេភូមិ ។

**បញ្ជាក់ :** មេភូមិ អាចពិចារណាបេក្ខជនមេភូមិដែលមិនបានជាប់ឆ្នោតឱ្យធ្វើជាបេក្ខជនជំនួយការមេភូមិ (ជាអនុប្រធានភូមិ ឬសមាជិកភូមិ) បើសាមីខ្លួនយល់ព្រម ។





**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ...................... ជាមេភូមិ...................... នៃឃុំ សង្កាត់........................ ។

**គោរពជូន**

**លោក លោកស្រីមេឃុំ ចៅសង្កាត់**--------------------

**កម្មវត្ថុ :** សំណើសុំដាក់បេក្ខជនជំនួយការមេភូមិ សម្រាប់ភូមិ...................................... ។

**យោង :** សេចក្តីសម្រេចលេខ.............. ចុះថ្ងៃទី........ ខែ...........ឆ្នាំ......... របស់ឃុំ សង្កាត់.................... ស្តីពីការតែងតាំងមេភូមិ................................. ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ នាងខ្ញុំ មានកិត្តិយស សូមជម្រាបជូនលោក លោកស្រី មេឃុំ ចៅសង្កាត់មេត្តាជ្រាបថា លោក លោកស្រីដែលមានឈ្មោះខាងក្រោមនេះ ពិតជាមានលក្ខណសម្បត្តិគ្រប់គ្រាន់ ជាបេក្ខជនជំនួយការមេភូមិ........................... ។

១). ........... (ឈ្មោះ) ............. ភេទ.......... អាយុ..........ឆ្នាំ ជាអនុប្រធានភូមិ

២). ........... (ឈ្មោះ) ............. ភេទ.......... អាយុ..........ឆ្នាំ ជាសមាជិកភូមិ

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាពិនិត្យ និងដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័ត ដោយសេចក្តីអនុគ្រោះ ។

សូមលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំបាទ នាងខ្ញុំ ។

ថ្ងៃទី------ ខែ---------- ឆ្នាំ------

**មេភូមិ**

(ហត្ថលេខា និងឈ្មោះ)

## ៥.៣. ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត

☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងអនុម័ត បេក្ខជនអនុប្រធានភូមិ និងសមាជិកភូមិ នៃភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ម្តងមួយភូមិៗ ក្នុងរយៈពេល**០៥ថ្ងៃ** បន្ទាប់ពីទទួលសំណើដាក់បេក្ខជនពីមេភូមិ ។

☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយលើកដៃលើបេក្ខជនអនុប្រធានភូមិ និងសមាជិកភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន តាមសម្លេងភាគច្រើនលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

☞ បើបេក្ខជនសម្រាប់មុខតំណែងជាអនុប្រធានភូមិ និងសមាជិកភូមិ នៃភូមិណាមួយ មិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសម្លេងភាគច្រើនលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួន ពិគ្រោះពិភាក្សាជាមួយជំទប់ ចៅសង្កាត់រង ដើម្បីណែនាំមេភូមិឱ្យ ដាក់ស្នើបេក្ខជនជាលើកទី២ ក្នុងរយៈពេល **០៥ថ្ងៃ**យ៉ាងយូរ ។





☞ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំ ដើម្បីពិនិត្យ និងអនុម័ត ទៅលើបេក្ខជនជំនួយការនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ**០៧ថ្ងៃ** បន្ទាប់ពីថ្ងៃដែលបានដាក់ស្នើបេក្ខភាព ។

☞ លើកទី២នេះ ប្រសិនបើបេក្ខជនដែលបានដាក់ស្នើនេះ នៅតែមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសម្លេងភាគច្រើនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលទេនោះ អធិបតីអង្គប្រជុំត្រូវស្នើឱ្យអង្គប្រជុំសម្រាកក្នុងរយៈពេលខ្លីមួយប្រហែល៣០នាទី ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានពេលវេលាសម្រាប់គិតពិចារណា និងពិគ្រោះយោបល់គ្នា។ បន្ទាប់មកអធិបតីអង្គប្រជុំ ត្រូវចាត់ឱ្យរៀបចំអនុម័តជាថ្មីម្តងទៀត ដោយសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានចូលរួមប្រជុំ ។

## ៥.៤. សេចក្តីសម្រេចតែងតាំងជំនួយការមេភូមិ

☞ បេក្ខជនជំនួយការមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តយល់ព្រមរួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចតែងតាំងជំនួយការមេភូមិនីមួយៗ ក្នុងរយៈពេល**០៧ថ្ងៃ** យ៉ាងយូរ បន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត ។

**បញ្ជាក់ :**

☞ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែង ត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស ។

☞ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែង អាចត្រូវជ្រើសរើសជាបេក្ខជនសម្រាប់មុខតំណែងមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិបាន ឱ្យតែជននោះ មានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមការណែនាំនេះ ។





**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង :............

ស្រុក ខណ្ឌ :............

ឃុំ សង្កាត់ :............

លេខ :.......ស.ស.រ

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងជំនួយការមេភូមិ**......(ឈ្មោះភូមិ).........

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ។
- យោងសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ។
- យោងកំណត់ហេតុអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នាថ្ងៃទី....... ខែ........... ឆ្នាំ........ ស្តីពីការពិនិត្យ និងអនុម័តជំនួយការមេភូមិ ។

**ស ម្រេ ច**

**ប្រការ ១** ..

ត្រូវបានតែងតាំងលោក លោកស្រី ដែលមានឈ្មោះខាងក្រោមនេះ ជាជំនួយការមេភូមិ នៃភូមិ ................................ ÷

១. ...........(ឈ្មោះ)......... ភេទ.......... អាយុ.........ឆ្នាំ ជាអនុប្រធានភូមិ

២. ...........(ឈ្មោះ)......... ភេទ.......... អាយុ.........ឆ្នាំ ជាសមាជិកភូមិ

**ប្រការ ២ ..**

អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- **អនុប្រធានភូមិ** ទទួលការងារជំនួសមេភូមិ ក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជម្ងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ ។ អនុប្រធានភូមិ ត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិ តាមគម្រោងផែនការរបស់ឃុំ សង្កាត់ ។
- **សមាជិកភូមិ** ជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ ។
- អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការផ្សេងៗទៀតដែលបានប្រគល់ឱ្យដោយមេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

**ប្រការ ៣ ..**

អនុប្រធានភូមិ សមាជិកភូមិ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី...... ខែ............ ឆ្នាំ......

**មេឃុំ ចៅសង្កាត់**

(ហត្ថលេខា)

(ត្រា)

(ឈ្មោះហត្ថលេខី)

**<u>ចម្លងជូន</u>**

- សាលាខេត្ត ក្រុង..................
- សាលាស្រុក ខណ្ឌ................

*"ដើម្បីជូនជ្រាប"*

- ដូចក្នុងប្រការ១

*"ដើម្បីអនុវត្ត"*

- ឯកសារ កាលប្បវត្តិ





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០០៤ ស.ជ.ន

**សេចក្តីណែនាំ**
**ស្តីពី**
**បែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ**
**ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង**
**ជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ**

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការផ្ទេរសមត្ថកិច្ចការ អំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងយោងតាមការសំរេចនៃកិច្ចប្រជុំគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់លើកទី ២១ កាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ដូចខាងក្រោម :

**១. <u>អំពីភូមិ</u>**

ភូមិ មិនមែនជាថ្នាក់រដ្ឋបាលដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ ។

ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន ។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានឃុំ ឬសង្កាត់មួយ ។

ភូមិនីមួយៗ ត្រូវគ្រប់គ្រងដោយមេភូមិម្នាក់ អមដោយអនុប្រធានភូមិម្នាក់ និងសមាជិកភូមិម្នាក់ជាជំនួយការ ។

**២. <u>បែបបទ និង នីតិវិធីនៃការជ្រើសរើសមេភូមិ</u>**

អនុលោមតាមមាត្រា ៣០ និងមាត្រា ៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី១នេះ ត្រូវធ្វើការជ្រើសរើសមេភូមិនៅគ្រប់ភូមិទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ការរៀបចំជ្រើសរើសមេភូមិ ត្រូវធ្វើឡើងតែនៅភូមិណាដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។

ផ្អែកតាមសេចក្តីណែនាំនេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវចាត់ឱ្យមេឃុំ ចៅ

សង្កាត់របស់ខ្លួន ធ្វើសេចក្ដីរាយការណ៍អំពីឈ្មោះភូមិដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។ ដើម្បីជ្រើសរើសមេភូមិសំរាប់ភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

**ក**-ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង របស់ខ្លួន រៀបចំជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិច ០៣ រូប សំរាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន ។

**ខ**-បេក្ខជនមេភូមិ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច ២៥ ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននេះ យ៉ាងតិច ០៦ ខែជាប់ៗគ្នា ។

**គ**-មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវពិគ្រោះពិភាក្សាគ្នាខិតខំជ្រើសរើសឱ្យមានស្ត្រីសំរាប់ជាបេក្ខជនមេភូមិ នៅភូមិនានានៃឃុំ សង្កាត់របស់ខ្លួន ។

**ឃ**-ក្រោយពីបានរៀបចំបេក្ខជនសំរាប់ភូមិនីមួយៗរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័តបង្កើតគណៈកម្មការបោះឆ្នោតដែលមានសមាជិកយ៉ាងច្រើនត្រឹម ០៣រូប ដោយមានស្មៀនឃុំ សង្កាត់ចូលរួមផងដែរ ។ គណៈកម្មការបោះឆ្នោត ត្រូវរៀបចំសន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវប្រើក្រដាសពណ៌ស ដែលមានទំហំប៉ុនគ្នា ដោយសរសេរនូវឈ្មោះបេក្ខជន (សរសេរដោយដៃ ឬដោយម៉ាស៊ីនអង្គុលីលេខ ឬដោយកុំព្យូទ័រ) ដែលបានដាក់ស្នើដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ទៅតាមលំដាប់អក្សរនៃឈ្មោះរបស់បេក្ខជនម្នាក់ៗ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗនោះ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សាមី ។ សន្លឹកឆ្នោតសំរាប់បេក្ខជននៃភូមិនីមួយៗ ត្រូវមានត្រារបស់ឃុំ សង្កាត់ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត ។

**ង**-បន្ទាប់ពីបានរៀបចំសន្លឹកឆ្នោតតាមភូមិនីមួយៗចំណុះឃុំ សង្កាត់ របស់ខ្លួនរួចហើយ គណៈកម្មការបោះឆ្នោត តាមរយៈមេឃុំ ចៅសង្កាត់ ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ដើម្បីរៀបចំបោះឆ្នោតជ្រើសរើសម្ដងមួយភូមិៗក្នុងរយៈពេលមិនឱ្យលើសពី ០៧ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ស្នើបេក្ខជននោះ ។

**ច**-មុនចាប់ផ្ដើមបោះឆ្នោតជ្រើសរើសមេភូមិ អធិបតីនៃអង្គប្រជុំត្រូវធ្វើសេចក្ដីរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន អំពីគោលការណ៍សំខាន់ៗនៃការបោះឆ្នោតជ្រើសរើសមេភូមិ រួចហើយត្រូវប្រគល់ភារកិច្ចជូនគណៈកម្មការបោះឆ្នោតដើម្បីរៀបចំនីតិវិធីដូចខាងក្រោម ៖

- សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យដូចៗគ្នានូវទំរង់ ទំហំ និងឈ្មោះបេក្ខជន ។
- រាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន អំពីឈ្មោះបេក្ខជនសំរាប់ភូមិនីមួយៗ ។
- សមាជិកក្រុមប្រឹក្សាម្នាក់ៗមានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយសន្លឹកសំរាប់ភូមិមួយដែលបានចែកជូនក្នុងពេលបោះឆ្នោត ។
- សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវគូសជ្រើសយកបេក្ខជនដែលខ្លួនគាំទ្រតែម្នាក់ប៉ុណ្ណោះលើសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោត ។
- សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល :
  + មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោត
  + គ្មានត្រារបស់ឃុំ សង្កាត់
  + គូសគាំទ្របេក្ខជនលើសពីម្នាក់
  + មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
  + មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត
  + រហែក ឬខូច
  + មានគំនូស តែគណៈកម្មការរៀបចំការបោះឆ្នោតមិនអាចកំណត់បានថាគាំទ្របេក្ខជនណាមួយ ។

**ឆ**-បន្ទាប់ពីបានណែនាំពីគោលការណ៍ នៃការបោះឆ្នោតជ្រើសរើសរួចរាល់ហើយ គណៈកម្មការបោះឆ្នោតត្រូវចែកសន្លឹកឆ្នោតជូនសមាជិកក្រុមប្រឹក្សាដែលមានវត្តមានក្នុងកិច្ចប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសមេភូមិម្ដងមួយភូមិៗ ។

**ជ**-ក្រោយពីសមាជិកក្រុមប្រឹក្សាគ្រប់ៗរូប ដែលមានវត្តមានក្នុងកិច្ចប្រជុំបានបោះឆ្នោតជ្រើសរើសរួចរាល់អស់ហើយ គណៈកម្មការបោះឆ្នោតត្រូវធ្វើការរាប់សន្លឹកឆ្នោតភូមិដែលបានបោះឆ្នោតនោះនៅចំពោះមុខអង្គប្រជុំ ដោយកត់ត្រាលទ្ធផលនៃការបោះឆ្នោត

ជ្រើសរើសមេភូមិនៃភូមិនីមួយៗនោះ នៅលើក្ដារខៀន ឬផ្ទាំងក្រដាសស រួចហើយអធិបតីនៃអង្គប្រជុំត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោតហើយភ្លាម ។

**ឈ**-បន្ទាប់មកអធិបតីនៃអង្គប្រជុំ ត្រូវចាត់ឱ្យគណៈកម្មការបោះឆ្នោត រៀបចំបោះឆ្នោតជ្រើសរើសមេភូមិផ្សេងទៀតដែលនៅសល់ជាបន្តបន្ទាប់រហូតគ្រប់ចំនួនភូមិដែលបានទទួលស្គាល់ជាផ្លូវការ ។

**ញ**- បេក្ខជនដែលជាប់ឆ្នោត គឺជាបេក្ខជនដែលមានសម្លេងឆ្នោតគាំទ្រច្រើនជាងគេ ហើយសម្លេងគាំទ្រនោះ ត្រូវមានចំនួនលើសពីពាក់កណ្ដាល នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

**ដ**-ក្នុងពេលរាប់សន្លឹកឆ្នោត ប្រសិនបេក្ខជនណាដែលមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្ដមានុភាព ។ ក្នុងករណីសម្លេងស្មើគ្នានោះជាបេក្ខ-ជនបុរស និងបេក្ខជនស្ត្រី បេក្ខជនស្ត្រីត្រូវបានជាប់ឆ្នោតជាមេភូមិ ។

**ឋ**-ចំពោះបេក្ខជនភូមិណាដែលមិនបានទទួលសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ចៅសង្កាត់រងដាក់ស្នើបេក្ខជនជាថ្មីសំរាប់ភូមិនោះ ទៅតាមបែបបទ នីតិវិធី ដូចមានចែងក្នុងចំណុច **ក ខ គ** និង **ឃ** ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំដើម្បីបោះឆ្នោតជ្រើសរើសលើបេក្ខជនមេភូមិនោះជាលើកទី២ ទៅតាមបែបបទ នីតិវិធីនៃការបោះឆ្នោតចាប់ពីចំណុច **ច** ដល់ចំណុច **ដ** ខាងលើ ក្នុងរយៈពេលយ៉ាងយូរ០៧ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតលើកទី១ ។

នៅក្នុងការបោះឆ្នោតលើកទី២នេះ ប្រសិនបើបេក្ខជននៅតែមិនបានទទួលសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាទាំងមូលទៀត អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ជ្រើសយកតែបេក្ខជនពីររូបដែលមានសម្លេងឆ្នោតគាំទ្របន្តបន្ទាប់គ្នាមកធ្វើការបោះឆ្នោតជ្រើសរើសសារឡើងវិញភ្លាម ។ ក្នុងការបោះឆ្នោតលើកចុងក្រោយនេះ បើគ្មានបេក្ខជនណាម្នាក់បានទទួលសម្លេងឆ្នោតគាំទ្រគ្រប់គ្រាន់ដូចមានចែងក្នុងចំណុច **ញ** ខាងលើនេះទេ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- សំរេចជ្រើសយកបេក្ខជនជាស្ត្រីធ្វើជាមេភូមិ បើក្នុងចំណោមបេក្ខជនទាំងពីរខាងលើនេះមានម្នាក់ជាស្ត្រី
- សំរេចជ្រើសយកបេក្ខជនដែលមានអាយុចាស់ជាងធ្វើជាមេភូមិ បើសិនជាបេក្ខជនទាំងពីរខាងលើនេះជាបុរស ។

បេក្ខជនមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោតជ្រើសរើស





រួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្ដីសំរេចតែងតាំងមេភូមិនីមួយៗនោះក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោត ។

## ៣. អំពីការតែងតាំងជំនួយការមេភូមិ

អនុលោមតាមមាត្រា ៣០ និង មាត្រា ៨៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវណែនាំមេភូមិនីមួយៗដែលបានទទួលការតែងតាំងជាផ្លូវការរួចហើយនោះ អោយធ្វើការដាក់បេក្ខជនជំនួយការរបស់ខ្លួនជាអនុប្រធាន និងសមាជិកភូមិ រួចហើយលើកសំណើដល់មេឃុំ ចៅសង្កាត់សាមីដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ពិនិត្យ និងអនុម័តក្នុងរយៈពេលយ៉ាងយូរ ០៧ ថ្ងៃ បន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះជាផ្លូវការ ។

ក្នុងការរៀបចំបេក្ខជនអនុប្រធាន និងសមាជិកភូមិនីមួយៗ មេភូមិ និងមេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានបេក្ខជនស្ត្រីយ៉ាងហោចណាស់ម្នាក់ សំរាប់មុខតំណែងអនុប្រធានភូមិ ឬសមាជិកភូមិ ចំពោះភូមិទាំងឡាយណាដែលមានមេភូមិជាបុរស ។

បេក្ខជនសំរាប់មុខតំណែងអនុប្រធាន និងសមាជិកភូមិ មានលក្ខណៈសម្បត្តិដូចគ្នានឹងមេភូមិ ដូចបានកំណត់ក្នុងចំណុច **ខ** នៃចំណុចទី២ ខាងលើ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយលើកដៃ លើបេក្ខជនអនុប្រធាន និងសមាជិកភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួន តាមសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបេក្ខជននេះ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងស្មើគ្នា សម្លេងអធិបតីនៃអង្គប្រជុំមានឧត្ដមានុភាព ។ ផ្ទុយទៅវិញប្រសិនបើបេក្ខជនសំរាប់មុខតំណែងជាអនុប្រធានភូមិ ឬសមាជិកភូមិនៃភូមិណាមួយដែលមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួនពិគ្រោះពិភាក្សាជាមួយជំទប់ចៅសង្កាត់រង ដើម្បីណែនាំមេភូមិឱ្យដាក់ស្នើបេក្ខជនជាលើកទី២ ក្នុងរយៈពេល ០៥ថ្ងៃយ៉ាងយូរ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំវិសាមញ្ញដើម្បីពិនិត្យ និងអនុម័តនៅលើបេក្ខជនជំនួយការនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ ០៧ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ស្នើបេក្ខភាព ។

លើកទី២នេះ ប្រសិនបើបេក្ខជនដែលបានដាក់ស្នើនេះនៅតែមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាទាំងមូលទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យបោះឆ្នោតគាំទ្រម្ដងទៀត ដោយសម្លេងភាគ

ច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានចូលរួម ។

បេក្ខជនជំនួយការមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តយល់ព្រមរួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្ដីសម្រេចតែងតាំងជំនួយការមេភូមិនីមួយៗនោះក្នុងរយៈពេល ០៧ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត ។

ប្រធាន អនុប្រធាន និងសមាជិកភូមិក្នុងមុខតំណែងត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស ។

ប្រធាន អនុប្រធាន និងសមាជិកភូមិក្នុងមុខតំណែង អាចត្រូវជ្រើសរើសជាបេក្ខជនសម្រាប់មុខតំណែងមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិបាន ឱ្យតែជននោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមការណែនាំនេះ ។

## ៤. អាណត្តិការងារ និង ការបាត់បង់មុខតំណែង

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាលាយល័ក្ខអក្សរ
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីភ្នាក់ងារមានសមត្ថកិច្ច
- សាមីខ្លួនត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់របស់ខ្លួន
- សាមីខ្លួនត្រូវតុលាការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សាមីខ្លួនផ្លាស់ទីលំនៅទៅភូមិផ្សេង
- សាមីខ្លួនមានកំហុសធ្ងន់ក្នុងការងារ ហើយត្រូវបញ្ឈប់ពីមុខតំណែងដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលអនុវត្តផ្ទុយពីតួនាទី ភារកិច្ច និងរបៀបរបបការងារដូចមានចែងក្នុងចំណុចទី ៥ នៃសេចក្ដីណែនាំនេះ ត្រូវចាត់ទុកថាមានកំហុសធ្ងន់ក្នុងការងារ ។

ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាមួយ ដែលបានប្រព្រឹត្តខុសធ្ងន់ក្នុងការងារ មេឃុំ ចៅសង្កាត់សាមី ត្រូវធ្វើការណែនាំជាលាយល័ក្ខអក្សរឱ្យសាមីខ្លួនកែលំអចំណុចខុសឆ្គងទាំងនោះ និងត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ក្នុងករណីដែលបានទទួលការណែនាំហើយ ប៉ុន្តែសាមីខ្លួននៅតែប្រព្រឹត្តខុសឆ្គងបន្តទៀតនោះ មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្ដីរាយការណ៍





ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះអញ្ជើញសាមីខ្លួនអោយមកទទួលការណែនាំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីឱ្យសាមីខ្លួនធ្វើការកែលំអកំហុសឆ្គង ។ ក្រោយពីបានទទួលការណែនាំពីក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ ប្រសិនបើសាមីខ្លួនមិនព្រមរាងចាល មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្នើសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចអនុម័ត បញ្ឈប់ជននោះពីមុខតំណែងតាមសម្លេងភាគច្រើននៃក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាម្នាក់ត្រូវបានបាត់បង់ពីមុខតំណែងតាមករណីណាមួយខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យធ្វើការជ្រើសរើសបេក្ខជនសម្រាប់កន្លែងដែលទំនេរនោះ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យអនុម័ត ក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ ស្របទៅតាមបែបបទ និងនីតិវិធី ដូចមានចែងក្នុងចំណុចទី២ និងចំណុចទី៣ នៃសេចក្ដីណែនាំនេះ ។

## ៥. តួនាទី ភារកិច្ច និង របៀបរបបការងាររបស់ភូមិ

ផ្អែកតាមមាត្រា ៣១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមាត្រា ២៣ ២៤ ២៥ ២៦ ២៧ ២៨ និងមាត្រា ២៩ នៃអនុក្រឹត្យស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបានកំណត់តួនាទី ភារកិច្ច និងរបៀបរបបការងារដូចខាងក្រោម ៖

- មេភូមិ ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្លងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ក្នុងការអនុវត្តការងារ មេភូមិត្រូវ ៖

១. បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន

២. ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្ដល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមាន ជាអាទិ៍ ៖

+ ផ្ដល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិអំពីតម្រូវការនិងផលប្រយោជន៍របស់ភូមិ

+ ផ្ដល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ

+ ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និងថវិកា អំពី :
  - តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងថវិកានិងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
  - អនុវត្តថវិកា និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
  - ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា និងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។

- មេភូមិត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មេភូមិត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

- មេភូមិត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងផ្សេងទៀតក្នុងនាមភូមិបានឡើយ ។

- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវជួបប្រជុំគ្នាយ៉ាងតិចមួយដងក្នុងមួយខែ ។

- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវធ្វើការពិគ្រោះឱ្យបានទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំឱ្យមានទីកន្លែងសំរាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ ។

ទីកន្លែងនោះ អាចជាទីស្នាក់ការភូមិ ចំពោះកន្លែងដែលមានទីស្នាក់ការភូមិ ។ ចំពោះកន្លែងដែលគ្មានទីស្នាក់ការភូមិ ត្រូវពិគ្រោះពិភាក្សាគ្នា ដើម្បីរកទីកន្លែងសមស្របណាមួយ ដែលអាចជាសាលារៀន វត្តអារាម វិហារសាសនា អគារសាធារណៈ ឬគេហដ្ឋានផ្ទាល់របស់មេភូមិ ។ ការជ្រើសរើសយកកន្លែងទាំងនោះ ត្រូវមានការពិគ្រោះពិភាក្សាឱ្យឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ ។ មេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយទីកន្លែងនោះដល់សាធារណៈជន ។

ទីកន្លែងនោះត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ត្រូវមានវត្តមាននៅទីកន្លែងដែលបាន





កំណត់នោះ នាថ្ងៃនោះ ដើម្បីជួបប្រជាពលរដ្ឋ ។

ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់នោះ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចនឹងជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់ ។

មេភូមិត្រូវធានាផ្តល់ពត៌មានជាឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារពត៌មានទាំងនោះអាចរួមមាន ពត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ។

មេភូមិ ពុំមានសិទ្ធិអំណាចសំរេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់បានឡើយ ។

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។

ដើម្បីធានាអនុវត្តនូវតួនាទី ភារកិច្ចខាងលើនេះ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបានធ្វើការបែងចែកប្រគល់ភារកិច្ចដូចខាងក្រោម ÷

- មេភូមិទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន

- អនុប្រធានភូមិទទួលជំនួសមេភូមិ ក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជា មានជម្ងឺ ឬមានបេសកកម្មក្រៅពីឃុំ សង្កាត់សាមី លើសពី ០១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគំរោងអភិវឌ្ឍន៍នានាក្នុងភូមិ តាមគំរោងផែនការរបស់ឃុំ សង្កាត់ ។

- សមាជិកភូមិទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ ។

ក្រៅពីការងារខាងលើនេះ មេភូមិអាចធ្វើការបែងចែក ប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី ។

## ៦. អំពីការបង្កើតភូមិថ្មី ការបង្រួម និង ការរំលាយភូមិ

ដើម្បីធានាដល់ការចាត់ចែងការងារ និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចលើកសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំលាយ និងបង្រួមភូមិ ចំណុះឃុំ

សង្កាត់របស់ខ្លួនបាន ប៉ុន្តែត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

**ក. ការបង្កើតភូមិថ្មី ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ :**

- មានលំនៅដ្ឋាន និងប្រជាពលរដ្ឋយ៉ាងតិច ១៥០គ្រួសារ ដែលប្រមូលផ្តុំគ្នានៅទីតាំងមួយសមស្រប ហើយដែលពិបាកដាក់បញ្ចូលនៅក្នុងភូមិណាមួយនៃឃុំ សង្កាត់ជាមួយ ឬឃុំ សង្កាត់ដែលជិតខាងជាប់គ្នា
- មិនត្រូវស្ថិតក្នុងទីតាំងដែលច្បាប់ហាមឃាត់
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលនៃភូមិដែលគ្រោងបង្កើតថ្មីនោះគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ជិតខាងដែលនៅជាប់គ្នា ។

**ខ. ការបំបែកភូមិ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ :**

- ភូមិដែលស្នើបំបែកនោះ មានប្រជាពលរដ្ឋច្រើនលើសលប់ ឬពិបាកគ្រប់គ្រង
- ក្រោយពេលបំបែកហើយ នៅសល់ចំនួនប្រជាពលរដ្ឋសមស្របយ៉ាងហោចណាស់ស្មើនឹងភូមិដែលបង្កើតថ្មីដែរ
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយជិតខាងដែលនៅជាប់គ្នា ។

**ឃ. ការរំលាយ និងការបង្រួមភូមិបញ្ចូលគ្នា ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :**

- មានចំនួនលំនៅដ្ឋាននិងគ្រួសារប្រជាពលរដ្ឋតិចពេក ឬមានភូមិសាស្ត្រឆ្ងាយពិបាកក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍
- ក្រោយពេលរំលាយ និងបង្រួមបញ្ចូលគ្នាហើយ មានចំនួនប្រជាពលរដ្ឋយ៉ាងហោចណាស់ស្មើនឹងភូមិដែលទើបបង្កើតថ្មី
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលនៃភូមិដែលត្រូវរំលាយ និង បង្រួមបញ្ចូលគ្នានោះគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយដែលនៅជិតខាងជាប់គ្នា ។

លក្ខណៈសម្បត្តិខាងលើនេះមិនត្រូវយកមកអនុវត្តចំពោះភូមិប្រជាពលរដ្ឋជនជាតិដើមភាគតិចឡើយ ។

មេឃុំ ចៅសង្កាត់នៅពេលដែលពិនិត្យឃើញមានតម្រូវការចាំបាច់ក្នុងការបង្កើតភូមិថ្មី ឬការបំបែក ឬរំលាយ និងបង្រួមភូមិ ត្រូវចាត់ឱ្យមានគណៈកម្មការមួយ ដើម្បីស្រាវជ្រាវ រៀបចំរបាយការណ៍ និងឯកសារផ្សេងៗទៅសុំការសំរេចពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់សំរេចឯកភាពលើសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំលាយភូមិ និងបង្រួមបញ្ចូលគ្នានោះ មេឃុំ ចៅសង្កាត់ត្រូវលើកសំណើទៅអភិបាល





ខេត្ត ក្រុងសាមី ។ ក្រោយពីទទួលបានសំណើ អភិបាលខេត្ត ក្រុងត្រូវចាត់អោយធ្វើការពិនិត្យ និងវាយតំលៃតាមលក្ខណៈវិនិច្ឆ័យខាងលើនេះ ។ ករណីពិនិត្យឃើញថា សំណើនេះមានលក្ខណៈសមស្របហើយ អភិបាលខេត្ត ក្រុងត្រូវសុំការសំរេចពីក្រសួងមហាផ្ទៃ ។ ការបង្កើតភូមិថ្មី ឬការបំបែក ឬការរំលាយ និងការបង្រួមភូមិ ត្រូវធ្វើដោយប្រកាសក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានហេតុផលគ្រប់គ្រាន់បញ្ជាក់ថា សំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំលាយ និងបង្រួមភូមិណាមួយដែលមិនស្របតាមលក្ខណៈវិនិច្ឆ័យ និងមិនអនុវត្តតាមបែបបទខាងលើនេះ ក្រសួងមហាផ្ទៃអាចបដិសេធសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំលាយ និងបង្រួមភូមិនោះ រួចហើយត្រូវណែនាំអោយរៀបចំសំណើជាថ្មី ឬអាចផ្អាកការបង្កើតភូមិថ្មី ឬការបំបែក ឬការរំលាយ និងបង្រួមភូមិនោះ ដោយភ្ជាប់ជាមួយនូវការណែនាំអំពីវិធានការចាំបាច់នានាក្នុងការលើកកំពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍ភូមិទាំងនោះ ។

យោងតាមសេចក្តីណែនាំនេះ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវនូវសេចក្តីណែនាំនេះ ។ អភិបាលខេត្ត ក្រុងនីមួយៗត្រូវផ្អែកតាមសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្ម ដូចមានចែងក្នុងប្រកាសក្រសួងមហាផ្ទៃលេខ ១៨៨៤ ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ដើម្បីជួយគាំទ្រដល់ឃុំ សង្កាត់អនុវត្តឱ្យបានសំរេចនូវសេចក្តីណែនាំនេះ ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពចាប់ថ្ងៃចុះហត្ថលេខា និងឡាយព្រះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ ២០០៦

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ទីស្តីការក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល "ដើម្បីជូនជ្រាប"
- អគ្គលេខាធិការដ្ឋាន
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល
- គ្រប់សាលាខេត្ត ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ